# ការផ្សព្វផ្សាយបោកបញ្ឆោតឱ្យធ្វើសកម្មភាព

ការផ្សព្វផ្សាយបោកបញ្ឆោតឱ្យធ្វើសកម្មភាពមិនមែនជារឿងដែលទើបនឹងមានក្នុងពេលសព្វថ្ងៃនេះទេ។ ខ្លឹមសារនិងរបៀបបញ្ឆោតមិនមានការប្រែប្រួលធំដុំទេ។ តែវិធីផ្សព្វផ្សាយមានការវិវត្តតាមការវិវត្តខាងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍។

ខ្លឹមសារនិងរបៀបបញ្ឆោត គឺការដាក់សំណូមពរឬណែនាំឱ្យធ្វើសកម្មភាពមួយឬច្រើនដោយប្រាប់អំពីផលចំណេញដែលនឹងទទួលបានពីការធ្វើតាមសំណូមពរនិងផលអាក្រក់ដែលនឹងទទួលបានពីការមិនបានធ្វើតាមសំណូមពរឬការណែនាំ។ គេច្រើនប្រាប់ថាអ្នកធ្វើសកម្មភាពតាមគេប្រាប់នឹងទទួលបានសក្តិយសខ្ពង់ខ្ពស់ឬមាសប្រាក់ឬទ្រព្យសម្បត្តិយ៉ាងច្រើន ឬរួចផុតពីគ្រោះថ្នាក់ឬការខាតបង់អ្វីមួយ ហើយអ្នកដែលមិនធ្វើតាមគេប្រាប់នឹងរងការខាតបង់សក្តិយសឬទទួលគ្រោះថ្នាក់ធំដែលអាចដល់ថ្នាក់បាត់បង់ជីវិត។

នៅចំពោះមុខការប្រាប់អំពីលទ្ធភាពចំណេញឬខាតនេះ អ្នកបានទទួលព័ត៌មានច្រើនតែធ្វើតាមសំណូមពរឬការណែនាំ ព្រោះម្យ៉ាងវាជាសំណូមពរឬកិច្ចការដែលគេអាចធ្វើបានដោយគេគ្រាន់តែចំណាយប្រាក់កាស និងពេលវេលាមួយចំនួនប៉ុណ្ណោះ ហើយការធ្វើតាមអាចនឹងធ្វើឱ្យគេជួបនឹងសំណាងល្អឬរួចផុតពីគ្រោះថ្នាក់ផ្សេងៗ ហើយម្យ៉ាងទៀត បើគេមិនធ្វើតាមការប្រាប់វិញ នោះគេអាចនឹងមានការខាតបង់ទ្រព្យសម្បត្តិឬមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងររហូតដល់បាត់បង់ជីវិត។

ទោះជាការផ្សាយបោកបញ្ឆោតខ្លះមិនមានការប្រាប់ឱ្យផ្សាយបន្តក៏ដោយ ក៏អ្នកទទួលព័ត៌មានភាគច្រើនបាននិយាយបន្តឬសរសេរប្រាប់ទៅអ្នកដទៃពិសេសអ្នកជិតស្និទ្ធ។

ចំពោះការផ្សាយបញ្ឆោតដោយដាក់សំណូមពរឱ្យធ្វើការផ្សព្វផ្សាយព័ត៌មានបន្តវិញ វិធីផ្សព្វផ្សាយបន្តមានការវិវត្តទៅតាមការវិវត្តខាងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍។ យ៉ាងណាមិញកាលពីសម័យដែលមិនទាន់មានម៉ាស៊ីនថតចម្លង បើគេចង់បានឯកសារសរសេរដើម្បីចែកដល់មនុស្សដប់នាក់ នោះគេត្រូវសរសេរចម្លងមួយចប់ៗដប់ដងប្រសិនបើគេគ្មានក្រដាសកាបោន។ ប៉ុន្តែបើមានក្រដាសកាបោន នោះអ្នកចម្លងចែកអាចធូរកម្លាំងបន្តិចព្រោះគេអាចផលិតបាន២ឬ៣ច្បាប់ដោយគ្រាន់តែសរសេរចម្លងមួយចប់។ សព្វថ្ងៃ គេច្រើនប្រើម៉ាស៊ីនថតចម្លងជំនួសការប្រើកម្លាំងសរសេរចម្លងដោយដៃ តែគេត្រូវចំណាយលុយកាក់ច្រើនជាងការចម្លងដោយដៃ។ បើផ្សាយអនឡាញវិញ នោះគេកាន់តែមានការងាយស្រួល ព្រោះគេគ្រាន់តែប្រើទូរស័ព្ទដៃឬកុំព្យូទ័រឱ្យចម្លងនិងបិទភ្ជាប់(copy and paste)អត្ថបទរួចបញ្ជូនឬឱ្យបញ្ជូនបន្តទៅកាន់មនុស្សតាមចំនួនដែលគេតម្រូវ។

នៅក្នុងរឿងផ្សព្វផ្សាយបោកបញ្ឆោតនេះ បញ្ហាសំខាន់ៗដែលយើងគួរដោះស្រាយមានជាអាទិ៍៖

+ផលវិបាកអវិជ្ជមានដែលបណ្តាលមកពីការបោកបញ្ឆោត ពិសេសការរំខាននិងមូមៅខាងផ្លូវ

ចិត្ត ការខាតបង់ពេលវេលា និងការចំណាយប្រាក់កាសទៅលើការធ្វើតាមសំណូមពរឬការណែនាំដូចជាការទិញក្រដាស ការចំណាយក្នុងការថតចម្លង ការចំណាយលើការប្រើទូរស័ព្ទ អ៊ីនធឺណិតសម្រាប់ការផ្សាយបន្តជាជាដើម

+ការពិបាកនៅក្នុងជម្រើសវិធានការសម្រាប់ទប់ស្កាត់ការផ្សាយបោកបញ្ឆោតនិងសម្រាប់កាត់បន្ថយចំនួនអ្នកចាញ់បោក ជាអាទ៍៖

-ការពិបាករកឱ្យឃើញថាតើគេបោកបញ្ឆោតក្នុងបំណងអ្វី

-ការពិបាកកំណត់ប្រភពដំបូងនៃការបោកបញ្ឆោត

-ការពិបាកក្នុងការពន្យល់ដើម្បីកុំឱ្យចាញ់បោក។

ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួននៃការផ្សព្វផ្សាយបោកបញ្ឆោតឱ្យធ្វើសកម្មភាព

-ការផ្សព្វផ្សាយឱ្យដាក់ស្លឹកទន្សែនៅមាត់របងឬមាត់ទ្វារផ្ទះដើម្បីកុំខ្មោចចូលយកជីវិតមនុស្ស

-ការផ្សព្វផ្សាយឱ្យចងអំបោះក្រហមនៅកកូនក្មេងដើម្បីកុំឱ្យគេមកសុំយកទៅបាត់

-ការផ្សព្វផ្សាយឱ្យនាំគ្នាហូបបបរសណ្តែកខៀវដើម្បីបានរួចពីគ្រោះថ្នាក់

-ការផ្សាយថាមានមេរោគនៅក្នុងថ្នាំប៉ារ៉ាសេតាម៉ុលដែលមានសញ្ញាP/500





-ការផ្សាយឱ្យបិទទូរសព្ទចាប់ពីម៉ោង០ៈ៣០ដល់ម៉ោង៣ៈ៣០ យប់ថ្ងៃទី២៥ ខែមករា




-ការផ្សាយប្រាប់ឱ្យផ្សាយបន្តថាខែកុម្ភៈខាងមុខជាខែកម្រ ព្រោះក្នុងខែនេះ ថ្ងៃទាំង៧សុទ្ធតែមាន៤ថ្ងៃដូចៗគ្នា



-ការផ្សាយប្រាប់កុំឱ្យហៅត្រឡប់ទៅលេខទូរសព្ទមួយចំនួន

ប្រកាសអាសន្ន ០:
ការិយាល័យប្រឆាំងការជួញដូរមនុស្សសូមជូនដំណឹងដល់អ្នកប្រើប្រាស់ទូរស័ព្ទទាំងអស់មេត្តាប្រុងប្រយ័ត្នចំពោះលេខទូរស័ព្ទហៅចូលទាំងនេះផង!

........................................................

សូមអាននិងត្រូវប្រុងប្រយ័ត្ន !!! សូមចែករំលែកព័ត៌មាននេះទៅ ក្រុមគ្រួសារនិងមិត្តភក្តិរបស់អ្នក។ មានមនុស្សជាច្រើនត្រូវបានទទួល ការហៅទូរស័ព្ទពី +37560260528 +37127913091 +37178565072 +56322553736 +37052529259 +255901130460 ឬលេខណាមួយ ដែលចាប់ផ្តើមពី +375, +371, +381។ នេះបើតាមបណ្តាញ សង្គមផ្លូវការ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន រាជធានីភ្នំពេញ។

ទូរស័ព្ទយើងពេលទទួលលេខនេះ គឺរោទ៍តែមួយដងប៉ុណ្ណោះ ហើយវានឹងបិទទៅវិញ។
ដូចនេះប្រសិនបើអ្នកហៅទៅកាន់លេខ ទាំងនេះវិញ លោកអ្នកនឹងត្រូវបង់សោរ $15 - $30 ។
ពួកគេអាច ចម្លងបញ្ជីទំនាក់ទំនងរបស់អ្នកនៅក្នុងរយៈពេលត្រឹមតែ3វិនាទី ។
ប្រសិនបើអ្នកមានលម្អិតធនាគារឬកាតឥណទាននៅក្នុងទូរស័ព្ទរបស់អ្នកពួកគេអាចចម្លងផងដែរ!
លេខទាំងនេះគឺមកពីប្រទេសបេឡារុស
+375 អាហ្វហ្កានីស្ថានកូដ
+371, Lativa,
+381 កូដសម្រាប់ប្រទេសស៊ែប៊ី
+563 កូដសម្រាប់ Valparaiso
+370 កូដសម្រាប់ Vilnius
+255 កូដសម្រាប់តង់ហ្សានី។

#ការហៅទូរស័ព្ទទាំងនេះប្រហែលអាចមកពីពួកISIS

សូមកុំឆ្លើយឬ Call ត្រឡប់ទៅវិញ។ សូមចែករំលែកពត៌មាននេះជាមួយមិត្តភក្តិនិងក្រុមគ្រួសាររបស់អ្នក។មួយវិញទៀតប្រសិនបើនរណាខ្លះសុំឱ្យអ្នកចុច #09 រឺ #90 សូមកុំចុចលេខនេះអោយសោះ។ នេះជាល្បិចថ្មីរបស់ជំ ពេញនិយមបំផុតរបស់ពួកភេរវករទៅលើអ្នកមិនដឹងអី ។ពួកភេរវករ បានប្រើប្រាស់ឧបករណ៍មួយគឺថានៅពេលដែលអ្នកចុច #09 រឺ 90# ពួកគេអាចចូលដំណើរការស៊ីមកាតរបស់អ្នកនិងធ្វើឱ្យការហៅទូរស័ព្ទរបស់ពួកគេគឺជាការចំណាយរបស់អ្នក។

បញ្ជូនសារនេះទៅមិត្តភក្តិជាច្រើនអោយ ត្រូវប្រុងប្រយ័ត្នក្នុងការទទួលទូរសព្ទ័ដែលមិនស្គាល់ដូចខាងលើ។ ពត៌មាននេះបានទូរទស្សន៍របស់សិង្ហបុរីបានផ្សព្វផ្សាយទៅកាន់ប្រជាពលរដ្ឋពួកគេទាំងអស់ដើម្បីជូនដំណឹងទៅឱ្យប្រុងជើងការហើយប្រុងប្រយ័ត្ន។

-ការផ្សាយថាមានការបញ្ចូលឈាមដែលផ្ទុកមេរោគអេដស៍ទៅក្នុងផ្លែឈើ។



-ការផ្សាយបោកបញ្ឆោតផ្សេងៗទៀត



Hello មានមនុស្សចំនួន 5
នាក់សួររកអ្នក ខ្ញុំ បានអោយ
អាស័យដ្ឋាន របស់អ្នកទៅពួក
គាត់ ពួកគាត់និងទៅរកអ្នកឆា
ប់ៗនេះ ពួកគាត់ មានឈ្មោះ
ថា សំណាង សប្បាយ ជោគជ័
យ សុភមង្គល និងក្តីស្រលា
ញ់។ ផ្ញើរសា នេះទៅមនុស្សដែ
លអ្នក ស្រលាញ់និងបារម្មណ៍
អោយបាន10នាក់ បើមិនផ្ញើរ
ទៅទេ និងមិនមានរបស់អស់
ទាំងនេះឡើយ



ក្នុងខែកក្កដានេះ អ្នកនិងមិនធ្លាប់ឃើញ
ឆ្នាំនេះ ខែកក្កដាមានថ្ងៃច័ន្ទ៥ថ្ងៃ ថ្ងៃពុធ៥ថ្ងៃ
ថ្ងៃព្រហស្បត៏៥ថ្ងៃ នេះជាព្រឹត្តិការណ៍
ដែលកើតឡើងក្នុងរយៈពេល៨២៣ឆ្នាំម្តង
នេះគឺជាការហៅលុយចូលហោប៉ៅ
ដូចនេះត្រូវបញ្ជូនសារនេះទៅឲ្យមិត្តភ័ក្រយ៉ាងតិច១៨
នាក់ ហើយលុយនិងហូរចូលក្នុងរយៈពេល៨ថ្ងៃ
តាមល័ក្ខខ័ណ្ឌរបស់គ្រូចីន អ្នកដែលមិន
បានបញ្ជូនសារនេះ
និងមានហាញ្ញាខាងលុយកាក់មួយជីវិត